**APA/២០០៧/០៩**

១៩ វិច្ឆិកា ២០០៧

# បទបញ្ជាផ្ទៃក្នុងនៃមហាសន្និបាតសភាតំបន់អាស៊ី (APA)

អនុម័តនៅមហាសន្និបាតលើកទី ២ នៃសភាតំបន់អាស៊ី ( ១៩-២១ ខែវិច្ឆិកា ឆ្នាំ ២០០៧ )
ទីក្រុងតេរ៉ង់ សាធារណរដ្ឋអ៊ីស្លាម អ៊ីរ៉ង់ ថ្ងៃច័ន្ទទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧

APA/២០០៧/០៩
១៩ វិច្ឆិកា ២០០៧

# បទបញ្ជាផ្ទៃក្នុងនៃមហាសន្និបាតសភាតំបន់អាស៊ី (APA)


I. សមាសភាព
II. សម័យប្រជុំពេញអង្គ
III. ប្រធានអង្គប្រជុំ និងភ្នាក់ងារអង្គប្រជុំ
IV. គណៈកម្មាធិការអចិន្ត្រៃយ៍
V. របៀបវារៈ សេចក្តីសម្រេច និងកិច្ចពិភាក្សា
VI. វិសោធនកម្ម
VII. នីតិវិធីនៃការបញ្ចេញមតិ និងសំណើ
VIII. កូរ៉ុម មតិឯកច្ឆ័ន (កុងសង់ស៊ីស) និងការបោះឆ្នោត
IX. លេខាធិការដ្ឋានអចិន្ត្រៃយ៍ និងលេខាធិការដ្ឋានបណ្តោះអាសន្ន
X. ការបិទសម័យប្រជុំពេញអង្គ
XI. ការអនុម័ត និងការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង


## I. សមាសភាព

**ប្រការ ១**

១-មហាសន្និបាត ត្រូវមានសមាសភាពចូលរួមដោយសភាមកពីប្រទេសក្នុងតំបន់អាស៊ី[1] ដែលជាសមាជិកនៃសភាតំបន់អាស៊ី ដែលពីនេះតទៅឲ្យឈ្មោះថា (APA) និងមានអាណត្តិចំនួន២ឆ្នាំ យោងទៅតាមមាត្រា៦ នៃធម្មនុញ្ញសភាតំបន់អាស៊ី។

២-សភាជាសមាជិកនីមួយៗ មានសិទ្ធិចាត់តាំងសមាជិកគណៈប្រតិភូសភាតំបន់អាស៊ីរបស់ខ្លួនចាប់ពី ២ (ពីរ) ដល់ ៧ (ប្រាំពីរ) រូប យោងតាមមាត្រា៨ នៃធម្មនុញ្ញសភាតំបន់អាស៊ី។

៣-សភាជាសមាជិក ត្រូវបញ្ជូនឈ្មោះ និងព័ត៌មានទំនាក់ទំនងគណៈប្រតិភូរបស់ខ្លួនជាលាយល័ក្ខអក្សរ ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ប៉ុន្តែឲ្យបានមួយខែយ៉ាងតិច មុនពេលមហាសន្និបាតចាប់ផ្តើម។

៤-មុនបញ្ចប់អាណត្តិ២ឆ្នាំជាគណៈប្រតិភូសភាតំបន់អាស៊ី បើសិនមានសមាជិកគណៈប្រតិភូសភាតំបន់អាស៊ីណាម្នាក់ បញ្ចប់អាណត្តិការងារក្នុងសភាជាតិរបស់ខ្លួន ឬដោយមូលហេតុមិនអាចបំពេញកាតព្វកិច្ចជាសមាជិកសភាជាតិរបស់ខ្លួន ឬដោយមូលហេតុទទួលមរណភាព សភាជាតិរបស់ប្រតិភូរូបនោះ ត្រូវតែងតាំងគណៈប្រតិភូថ្មីផ្សេងទៀតសម្រាប់អណត្តិ២ឆ្នាំ ហើយត្រូវផ្តល់ដំណឹងអំពីសមាជិកប្រតិភូថ្មីនោះជាលាយល័ក្ខអក្សរ ទៅកាន់អគ្គលេខាធិការសភាតំបន់អាស៊ី។

[1] ពាក្យថា “អាស៊ី” នៅក្នុងបទបញ្ជា និងធម្មនុញ្ញនេះសំដៅលើប្រទេសអធិប្បតេយ្យនៅក្នុងតំបន់អាស៊ី និងក្រុមអាស៊ីប៉ាស៊ីហ្វិកដូចដែលបានអនុវត្ត និងចែងដោយអង្គការសហប្រជាជាតិ ក៏ដូចជាប្រទេសអធិប្បតេយ្យទាំងឡាយដែលមានទឹកដីមួយផ្នែកស្ថិតក្នុងតំបន់អាស៊ី។

ប្រការ ២

១- សមាជិកអ្នកអង្កេតការណ៍នៃសភាតំបន់អាស៊ី អាចចូលរួមកម្មវិធីបើកសម័យប្រជុំពេញអង្គ និងកិច្ចប្រជុំគណៈកម្មាធិការនានា ក្នុងនាមជាអ្នកអង្កេតការណ៍ ហើយអាចថ្លែងសុន្ទរកថាបានលុះត្រាណាមានការអញ្ជើញពីប្រធានកិច្ចប្រជុំ។ សមាជិកអង្កេតការណ៍មិនអាចបោះឆ្នោត ឬដាក់បេក្ខភាពសម្រាប់ការបោះឆ្នោតចូលក្នុងភ្នាក់ងារអង្គប្រជុំមហាសន្និបាតបានឡើយ។

២-តំណាងអង្គការក្នុងតំបន់ និងអង្គការអន្តរជាតិ ឬតំណាងមកពីសហភាពអន្តរសភា អាចនឹងត្រូវបានគេអញ្ជើញ ក្នុងនាមជាអ្នកអង្កេតការណ៍ ឲ្យចូលរួមកម្មវិធីបើកមហាសន្និបាត អាស្រ័យដោយមានការផ្តល់យោបល់ពីភ្នាក់ងារនៃអង្គប្រជុំកាលពីឆ្នាំកន្លងទៅ និងមានការទទួលស្គាល់ពីមហាសន្និបាតដែលពួកគេមានបំណងចង់ចូលរួម។

៣-ពាក្យស្នើសុំជាសមាជិកភាព ឬស្នើសុំជាអ្នកអង្កេតការណ៍សភាតំបន់អាស៊ី ត្រូវបញ្ជូនពាក្យស្នើសុំជាលាយល័ក្ខអក្សរទៅកាន់ប្រធានសភាតំបន់អាស៊ី ហើយសំណើនោះនឹងត្រូវពិនិត្យ និងពិចារណានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិបន្ទាប់ ដែលនឹងផ្តល់អនុសាសន៍ដល់កិច្ចប្រជុំពេញអង្គសភាតំបន់អាស៊ីដើម្បីសម្រេច។ ពាក្យស្នើសុំនេះ នឹងត្រូវអនុម័តដោយសម្លេងភាគច្រើននៃសមាជិកគណៈប្រតិភូសភាតំបន់អាស៊ីដែលមានវត្តមានក្នុងកិច្ចប្រជុំពេញអង្គ ហើយការបោះឆ្នោត ត្រូវស្របតាមប្រការទី៣៤(៣) នៃបទបញ្ជាផ្ទៃក្នុងសភាតំបន់អាស៊ី។

ប្រការ ៣

សមាជិកសភាតំបន់អាស៊ី អាចជ្រើសតាំងអតីតសមាជិកសភារបស់ខ្លួន ព្រមទាំងអ្នកតំណាងមកពីអង្គការក្រៅរដ្ឋាភិបាល បញ្ញាជន អ្នកវិទ្យាសាស្រ្ត និងឥស្សរជន ឲ្យធ្វើជាសមាជិកកិត្តិយសក្នុងគណៈប្រតិភូរបស់ខ្លួន។

## II. **សម័យប្រជុំ**

ប្រការ ៤

មហាសន្និបាត ត្រូវធ្វើឡើងរៀងរាល់ឆ្នាំ (មាត្រា ៩ នៃធម្មនុញ្ញសភាតំបន់អាស៊ី)។ មហាសន្និបាត ត្រូវប្រព្រឹត្តឡើងរយៈពេល២ឆ្នាំជាប់ៗគ្នា នៅក្នុងប្រទេសសមាជិកដែលជាប្រធានសភាតំបន់អាស៊ី (មាត្រា ១០ នៃធម្មនុញ្ញសភាតំបន់អាស៊ី)។

**បញ្ជាក់៖** ក្នុងករណីប្រទេសជាម្ចាស់ផ្ទះ មិនអាចធ្វើការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតសភាតំបន់អាស៊ី ក្នុងរយៈពេល២ឆ្នាំជាប់ៗគ្នាបាន បេក្ខភាពជាប្រធានមហាសន្និបាត និងការរៀបចំកិច្ចប្រជុំ អាចធ្វើការប្រគល់ជូនទៅកាន់សភាជាសមាជិកផ្សេងទៀត ដោយសម្លេងភាគច្រើននៃសមាជិកសភាតំបន់អាស៊ី។

ប្រការ ៥

បន្ទាប់ពីបានពិភាក្សាជាមួយសមាជិកសភាតំបន់អាស៊ី ប្រធានសភាតំបន់អាស៊ី ត្រូវជូនដំណឹងទៅកាន់សមាជិករបស់ខ្លួនអំពីកាលបរិច្ឆេទនៃមហាសន្និបាតយ៉ាងតិច៣ខែមុនកិច្ចប្រជុំ។

**ប្រការ ៦**

ទីកន្លែង និងកាលបរិច្ឆេទនៃមហាសន្និបាត អាចនឹងមានការផ្លាស់ប្តូរ ក្នុងករណីចាំបាច់ ដោយមានការស្នើសុំពីភ្នាក់ងារកិច្ចប្រជុំ ក្រោមកិច្ចពិភាក្សាជាមួយសភាម្ចាស់ផ្ទះ និងដោយមានការឯកភាពពីមតិភាគច្រើននៃសភាជាសមាជិកសភាតំបន់អាស៊ី ស្របតាមប្រការ ១០ (២)។

**ប្រការ ៧**

១-ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសមាសភាពចូលរួមដោយសមាជិកគណៈប្រតិភូចំនួន០១រូប មកពីសមាជិកសភាតំបន់អាស៊ីនីមួយៗ។

២-ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានកិច្ចប្រជុំឲ្យបានយ៉ាងតិច ០២ លើក ក្នុងរយៈពេល១ឆ្នាំ។ កិច្ចប្រជុំលើកទីមួយ ត្រូវធ្វើឡើងភ្លាមៗមុនមហាសន្និបាត ហើយកិច្ចប្រជុំមួយលើកទៀត ជាទូទៅត្រូវធ្វើឡើងយ៉ាងតិចណាស់៣ខែមុនមហាសន្និបាត។

៣- យោងតាមកថាខណ្ឌទី១ និងទី២ កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ មានភារកិច្ចដូចតទៅះ

* ដឹកនាំការងារលេខាធិការដ្ឋាន ដើម្បីសម្រួលដល់ដំណើរការរៀបចំកិច្ចប្រជុំពេញអង្គប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។

* ពិនិត្យរបាយការណ៍ និងឯកសារដែលរៀបចំឡើងដោយលេខាធិការដ្ឋាន និងផ្តល់នូវអនុសាសន៍សមស្របដល់មហាសន្និបាតដើម្បីសម្រេច។

* ពិនិត្យសេចក្តីព្រាងសេចក្តីសម្រេច និងផ្តល់អនុសាសន៍សមស្រប ដើម្បីដាក់ជូនមហាសន្និបាតសម្រេច។

* ពិនិត្យសំណើសុំបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មីមួយទៀត ឬអនុគណៈកម្មការ គណៈកម្មការ ឬអង្គភាពក្រោមឱវាទណាមួយ។

* ពិនិត្យសំណើសុំចូលជាសមាជិកថ្មី ឬអ្នកអង្កេតការណ៍ និងផ្តល់អនុសាសន៍សមស្រប ដើម្បីដាក់ជូនមហាសន្និបាតសម្រេច។

* ពិនិត្យសេចក្តីស្នើសុំរបស់លេខាធិការដ្ឋាន អំពីសេចក្តីព្រាងរបៀបវារៈ នៃមហាសន្និបាត និងផ្តល់អនុសាសន៍ដល់មហាសន្និបាត ទៅលើសេចក្តីព្រាងរបៀបវារៈ។

* ពិនិត្យគម្រោងថវិកា និងហិរញ្ញវត្ថុរបស់សភាតំបន់អាស៊ី និងផ្តល់ជាអនុសាសន៍សមស្រប ដើម្បីដាក់ជូនមហាសន្និបាតសម្រេច។

* ផ្តល់អនុសាសន៍ដល់អគ្គលេខាធិការសភាតំបន់អាស៊ី ដើម្បីធ្វើការអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គ។

៤-សេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមតែអាចធ្វើទៅបានដោយមតិឯកច្ឆ័ន្ទ។ បើមិនដូច្នោះទេ ក្រុមប្រឹក្សាប្រតិបត្តិធ្វើសេចក្តីសម្រេចទៅតាមមតិភាគច្រើននៃសភាជាសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត។ ក្នុងករណីពិសេសដែលតម្រូវឲ្យមានការបោះឆ្នោតដោយមតិភាគច្រើន ២/៣ ត្រូវកំណត់ឡើងដោយមតិភាគច្រើនពីគណៈប្រតិភូដែលចូលរួម និងបានបោះឆ្នោត។

៥-សភាជាសមាជិកនីមួយៗ មានសំឡេងឆ្នោតតែ០១សម្លេងគត់ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។

៦-កូរ៉ុមសម្រាប់មហាសន្និបាត និងសម្រាប់ការអនុម័តទៅលើសេចក្តីសម្រេចដែលមានចែងក្នុងប្រការ ៣២ និង ៣៣ នៃបញ្ញាផ្ទៃក្នុងនេះ ត្រូវយកមកអនុវត្តផងដែរ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិនេះ។

### ប្រការ ៨

១-ការកោះអញ្ជើញសម្រាប់មហាសន្និបាតនីមួយៗ ត្រូវផ្ញើលិខិតអញ្ជើញទៅកាន់គ្រប់សភាជាសមាជិក សមាជិកអង្កេតការណ៍ និងអ្នកដែលត្រូវអញ្ជើញផ្សេងទៀត ឲ្យបានយ៉ាងតិច០១ខែមុនពេលមហាសន្និបាតចាប់ផ្តើម។

### ប្រការ ៩

សភាជាសមាជិកដែលជាម្ចាស់ផ្ទះទទួលរៀបចំមហាសន្និបាត មានភារៈសម្របសម្រួលចាំបាច់ផ្សេងៗ សម្រាប់មហាសន្និបាត។ សភាជាសមាជិកផ្សេងៗទៀតអាចស្មគ្រចិត្តជួយសម្រួលដល់ការចំណាយមួយផ្នែកណាមួយក្នុងការរៀបចំសម័យប្រជុំពេញអង្គនេះ។

### ប្រការ ១០

១-សមាជិក «អេភីអេ» ណាក៏ដោយ អាចស្នើសុំរៀបចំមហាសន្និបាតវិសាមញ្ញាបាន។ សភាជាសមាជិកដែលទទួលជាម្ចាស់ផ្ទះមហាសន្និបាតកាលពីលើកមុន អាចទទួលរៀបចំមហាសន្និបាតវិសាមញ្ញទៀតបាន ប្រសិនបើការស្នើសុំនេះ មានការគាំទ្រពីមតិភាគច្រើននៃសភាជាសមាជិក ( មាត្រា ៩ នៃធម្មនុញ្ញសភាតំបន់អាស៊ី)។ មហាសន្និបាតវិសាមញ្ញ អាចទទួលរៀបចំដោយសមាជិកផ្សេងទៀតក៏បាន ប្រសិនបើការស្នើសុំនេះ មានការឯកភាពពីប្រធានសភាតំបន់អាស៊ីដែលជាម្ចាស់ផ្ទះរៀបចំ កាលពីពេលកន្លងមក និងមានការឯកភាពពីមតិភាគច្រើននៃសភាជាសមាជិក។

២-ការគាំទ្រ ឲ្យមានការរៀបចំមហាសន្និបាតវិសាមញ្ញ និងការកំណត់ទីកន្លែងកិច្ចប្រជុំសមស្រប ត្រូវកំណត់តាមមូលដ្ឋានគ្រឹះនៃការមិនមានការជំទាស់ពីមតិភាគច្រើនរបស់សភាជាសមាជិកដែលបានឆ្លើយតប ចំពោះសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរដែលបានផ្ញើដោយលេខាធិការដ្ឋាន ទៅកាន់សភាជាសមាជិកទាំងអស់ដើម្បីស្នើសុំយោបល់ ទៅលើកម្មវត្ថុខាងលើ ដោយមានការកំណត់កាលបរិច្ឆេទឆ្លើយតបជាក់លាក់។ បើសិនមិនមានសភាជាសមាជិកលើសពីពាក់កណ្តាលជំទាស់ តាមរយៈការឆ្លើយតបជាលាយល័ក្ខអក្សរទៅកាន់លេខាធិការដ្ឋាន ចំពោះការស្នើរៀបចំមហាសន្និបាតវិសាមញ្ញ ឬការកំណត់ទីកន្លែងរៀបចំកិច្ចប្រជុំទេនោះ គេអាចសន្និដ្ឋានថាសភាជាសមាជិកភាគច្រើនបានគាំទ្រទៅលើសំណើរៀបចំមហាសន្និបាតវិសាមញ្ញ។

## III. ប្រធានអង្គប្រជុំ

### ប្រការ ១១

១-ប្រធានសភាតំបន់អាស៊ី ត្រូវបានជ្រើសរើសពីចំណោមប្រធានសភា នៃសភាជាសមាជិក សម្រាប់អាណត្តិ ០២ឆ្នាំ ដោយការអបអរសាទរ ឬដោយការបោះឆ្នោតដែលទទួលបានការគាំទ្រពីសម្លេងភាគច្រើននៃប្រតិភូដែលបានចូលរួម នៅក្នុងសម័យប្រជុំដំបូងនៃមហាសន្និបាត។

២-ប្រធានអង្គប្រជុំចប់អាណត្តិ ឬក្នុងករណីអវត្តមានរបស់គាត់ ប្រធានគណៈប្រតិភូរបស់ប្រធានអង្គប្រជុំចប់អាណត្តិនោះ ត្រូវបើកសម័យប្រជុំ ក្នុងរយៈពេលរង់ចាំការបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំថ្មី។

៣-មហាសន្និបាត ត្រូវធ្វើការជ្រើសរើសអនុប្រធានចំនួន ០៤ រូប (មាត្រា ១០ នៃធម្មនុញ្ញសភាតំបន់អាស៊ី) ពីក្នុងចំណោមប្រធានគណៈប្រតិភូ និងជ្រើសរើសអ្នករាយការណ៍ (Rapporteur) ចំនួន ០១ រូប ពីក្នុងចំណោមគណៈប្រតិភូ ដោយគិតពីសមភាពល្បាយភូមិសាស្ត្រ។

## ប្រការ ១២

១-ប្រធានសភាតំបន់អាស៊ី ត្រូវធ្វើជាប្រធានមហាសន្និបាតវិសមញ្ញផងដែរក្នុងអំឡុងអាណិត្តការងាររបស់ខ្លួន។

## ប្រការ ១៣

១- ភ្នាក់ងារដឹកនាំកិច្ចប្រជុំ ត្រូវមានប្រធានសភាតំបន់អាស៊ី អនុប្រធាន០៤រូប និងអ្នករាយការណ៍០១រូប ដែលនឹងត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់អាណិត្ត០២ឆ្នាំ តាមគោលការណ៍សមភាពល្បាយភូមិសាស្ត្រ។

២-ភ្នាក់ងារអង្គប្រជុំសភាតំបន់អាស៊ី ដែលទទួលបានការជួយគាំទ្រពីអគ្គលេខាធិការ ត្រូវមានវិធានការណ៍សមស្រប ដើម្បីធានាពីប្រសិទ្ធិភាពនៃការរៀបចំ និងការប្រព្រឹត្តទៅជាប្រក្រតីនៃដំណើរការកិច្ចប្រជុំ ស្របតាមធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងសភាតំបន់អាស៊ី។

## ប្រការ ១៤

១-ប្រធានអង្គប្រជុំ ត្រូវធ្វើការបើក ពន្យា ឬបិទសម័យប្រជុំ ដឹកនាំកិច្ចប្រជុំពេញអង្គ ធានាការគោរពបទបបញ្ជា និងនីតិវិធីកិច្ចប្រជុំ កោះអញ្ជើញប្រធានសភាឡើងថ្លែងបទអន្តរាគមន៍ ដាក់ស្នើការបោះឆ្នោត ប្រកាសលទ្ធផលបោះឆ្នោត និងប្រកាសបិទកិច្ចប្រជុំពេញអង្គ។ ការសម្រេចរបស់ប្រធានអង្គប្រជុំ ទៅលើបញ្ហានានា គឺជាការសម្រេចចុងក្រោយ។

២-ប្រធានអង្គប្រជុំ អាចធ្វើការសម្រេចលើបញ្ហាដ៏ទៃទៀតរបស់សភាតំបន់អាស៊ី ដែលមិនបានដាក់បញ្ចូលនៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ បន្ទាប់ពីទទួលការផ្តល់យោបល់ពីភ្នាក់ងារអង្គប្រជុំ។

# IV. គណៈកម្មាធិការអចិន្ត្រៃយ៍ អនុគណៈកម្មាធិការ គណៈកម្មការ និងអង្គភាពក្រោមឱវាទ

ប្រការ ១៥

១- ក្រៅពីគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងប្រាំ៖ (១) **គណៈកម្មការនយោបាយ** (២) **គណៈកម្មការសន្តិភាព និងសន្តិសុខ** (៣) **គណៈកម្មការសង្គម និងវប្បធម៌** (៤) **គណៈកម្មការសេដ្ឋកិច្ច និងការអភិវឌ្ឍដោយនិរន្តរភាព និង** (៥) **គណៈកម្មការថាមពល** មហាសន្និបាតអាចបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ អនុគណៈកម្មាធិការ គណៈកម្មការ និងអង្គភាពក្រោមឱវាទផ្សេងៗទៀតបាន បើសិន កិច្ចប្រជុំយល់ឃើញថា មានភាពចាំបាច់ ដើម្បីធ្វើការទៅលើប្រធានបទណាមួយដែលកិច្ចប្រជុំយល់ថា សំខាន់ និងដើម្បីពិនិត្យលើបញ្ហានានានៅក្នុងរបៀបវារៈកិច្ចប្រជុំ។ អង្គភាពទាំងនេះ ត្រូវដាក់របាយការណ៍ និងអនុសាសន៍របស់ខ្លួនទៅកាន់មហាសន្និបាត ដើម្បីពិនិត្យ និងសម្រេច។

២- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីភ្នាក់ងារអង្គប្រជុំរបស់មហាសន្និបាត ឬពីសភាជាសមាជិកយ៉ាងតិច ១០ ប្រទេស ការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអនុគណៈកម្មាធិការ គណៈកម្មការ និងអង្គភាពក្រោមឱវាទផ្សេងៗទៀត បញ្ហានេះត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។ អនុសាសន៍របស់ក្រុមប្រឹក្សាប្រតិបត្តិទៅលើបញ្ហានេះ ត្រូវអនុម័តដោយសម្លេងភាគច្រើនពីគណៈប្រតិភូដែលចូលរួម និងដែលបានបោះឆ្នោតក្នុងមហាសន្និបាត។

៣- កិច្ចប្រជុំចន្លោះសម័យប្រជុំរបស់អនុគណៈកម្មាធិការ គណៈកម្មការ និងអង្គភាពក្រោមឱវាទ ត្រូវរៀបចំធ្វើឡើង ដោយសភាដែលទទួលរៀបចំធ្វើជាម្ចាស់ផ្ទះមហាសន្និបាតកាលពីឆ្នាំកន្លងទៅ លើកលែងតែមានការឯកភាពរវាងប្រធាន និងលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដែលកិច្ចប្រជុំនោះអាចត្រូវរៀបចំ ដោយសភាជាសមាជិកដទៃទៀត។

៤- មហាសន្និបាត ត្រូវអនុម័តចំនួនសមាជិកភាព នៃអនុគណៈកម្មាធិការ គណៈកម្មការ និងអង្គភាពក្រោមឱវាទនីមួយៗ ដោយត្រូវពិចារណាអំពីសមភាពល្បាយភូមិសាស្ត្រ រយៈពេល និងចំនួនកិច្ចប្រជុំចន្លោះសម័យប្រជុំ។

## V. របៀបវារៈ សេចក្ដីសម្រេចចិត្ត កិច្ចពិភាក្សា

### ប្រការ ១៦

១-ដោយមានការផ្ដល់អនុសាសន៍ពីអគ្គលេខាធិការ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវរៀបចំសេចក្ដីព្រាងរបៀបវារៈមួយដែលរួមបញ្ចូលកិច្ចពិភាក្សាទូទៅដែលត្រូវចែកជូនសភាជាសមាជិក និងអ្នកអង្កេតការណ៍ ដើម្បីអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គ។

២-សេចក្ដីព្រាងរបៀបវារៈ ត្រូវផ្ញើទៅសភាជាសមាជិកទាំងអស់ តាមរយៈលេខាធិការដ្ឋានឲ្យបានយ៉ាងតិច២ខែ មុនមហាសន្និបាតចាប់ផ្ដើម។

៣-មហាសន្និបាត អាចធ្វើការកែប្រែ ឬសម្រេចទៅសេចក្ដីព្រាងរបៀបវារៈដែលបានស្នើនៅក្នុងពេលចាប់ផ្ដើម នៃកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។

៤-សម័យប្រជុំវិសាមញ្ញ អាចពិនិត្យរបៀបវារៈដែលខ្លួនត្រូវធ្វើការរៀបចំតែប៉ុណ្ណោះ។

### ប្រការ ១៧

១-សភាជាសមាជិក អាចបញ្ជូនសំណើទៅកាន់លេខាធិការដ្ឋាន ដើម្បីដាក់បញ្ចូលជាប្រធានបទបន្ថែមក្នុងសេចក្ដីព្រាងរបៀបវារៈ យ៉ាងតិច០២ខែមុនពេលមហាសន្និបាតចាប់ផ្ដើម។ សេចក្ដីថ្លែងហេតុ និងសេចក្ដីព្រាងសេចក្ដីសម្រេច ត្រូវដាក់ភ្ជាប់មកជាមួយសំណើនោះ។

២-សំណើសុំដាក់បញ្ចូលនូវប្រធានបទបន្ថែម ដែលលេខាធិការទទួលបានយ៉ាងតិច ៣០ថ្ងៃ មុនពេលដែលមហាសន្និបាតចាប់ផ្ដើម ឬសំណើសុំបញ្ចូលជាប្រធានបទបន្ទាន់ ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍សំខាន់ជាក់លាក់ណាមួយ ដែលកំពុងកើតមានឡើងក្នុងអំឡុងពេល ៣០ថ្ងៃ មុនពេលដែលមហាសន្និបាតចាប់ផ្ដើមឡើង ចាំបាច់ត្រូវអនុម័ត ដោយសម្លេង ២/៣ នៃសភាជាសមាជិកដែលមានវត្តមានចូលរួម ដោយការបោះឆ្នោត នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិដែលរៀបចំឡើងមុនមហាសន្និបាត។

### ប្រការ ១៨

មុនពេលសម្រេចចិត្តទៅលើសំណើសុំដាក់បញ្ចូលប្រធានបទបន្ថែម ឬប្រធានបទបន្ទាន់ណាមួយ ដោយផ្អែកទៅលើប្រការ១៧ខាងលើ កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និង មហាសន្និបាតត្រូវស្ដាប់អំពីសេចក្ដីថ្លែងការណ៍ពន្យល់សង្ខេបពីម្ចាស់សំណើនេះ និងសេចក្ដីថ្លែងការណ៍ពីប្រធានសភាមួយ ដោយប្រកាន់នូវគំនិតផ្ទុយគ្នា ដោយបង្ហាញថា មិនមានសំណើណាមួយប៉ះពាល់ទៅបញ្ហា ឬប្រធានបទឡើយ។

ប្រការ ១៩

១-គណៈប្រតិភូ អាច ដាក់សំណើ (ញត្តិ) ឬសេចក្តីព្រាងសេចក្តីសម្រេច ទាក់ទងប្រធានបទណាមួយដែលបានដាក់បញ្ចូលទៅក្នុងរបៀបវារៈ។

២-សេចក្តីព្រាងសេចក្តីសម្រេច ដែលទាក់ទងនឹងកម្មវត្ថុនៅក្នុងរបៀបវារៈ ជាទូទៅតាមច្បាប់ ត្រូវធ្វើការដាក់ផ្ញើទៅកាន់លេខាធិការដ្ឋានជាមុន យ៉ាងតិចឲ្យបាន ២៤ ម៉ោង មុនពេលដែលមហាសន្និបាតធ្វើការបើកទៅលើកម្មវិធីចុងក្រោយ ដើម្បីធ្វើការពិភាក្សាទៅលើកម្មវត្ថុនេះ។

ប្រការ ២០

១-នីតិវិធីនៃការដាក់ស្នើនូវសេចក្តីព្រាងសេចក្តីសម្រេច ទៅលើប្រធានបទបន្ថែម ឬប្រធានបទបន្ទាន់ណាមួយ ត្រូវសម្រេចដោយមហាសន្និបាត ដោយមានអនុសាសន៍ពីភ្នាក់ងារអង្គប្រជុំនៃមហាសន្និបាត។

២-រាល់ប្រធានបទបន្ថែម ឬបន្ទាន់ អាចត្រូវប្រគល់ជូនគណៈកម្មការចំពោះកិច្ច ដើម្បីពិភាក្សាវែកញែក និងរៀបចំជារបាយការណ៍ ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីឲ្យមហាសន្និបាតពិនិត្យពិចារណា។

ប្រការ ២១

១-មហាសន្និបាត ត្រូវចាប់ផ្តើមដោយមានកិច្ចពិភាក្សាទូទៅ ដែលគណៈប្រតិភូទាំងអស់អាចថ្លែងអំពីបញ្ហានានាពាក់ព័ន្ធនយោបាយ សន្តិសុខ-សេដ្ឋកិច្ច និងសង្គម-វប្បធម៌ ដោយផ្អែកទៅលើគោលការណ៍ និងគោលបំណងនៃការបង្កើត **សភាតំបន់អាស៊ី** APA ដែលមានចែងនៅក្នុងធម្មនុញ្ញរបស់សភាតំបន់អាស៊ី (មាត្រា២ និងមាត្រា៣ នៃធម្មនុញ្ញសភាអាស៊ី)។

២-មហាសន្និបាត ត្រូវលើកកម្ពស់កិច្ចសន្ទនាប្រកបដោយលក្ខណៈមិត្តភាព និងស្ថាបនា។ ដើម្បីសម្រេចបានគោលដៅនេះ គណៈប្រតិភូមិនត្រូវថ្លែងអំពីបញ្ហាវិវាទជាលក្ខណៈទ្វេភាគីជាដាច់ខាត។

## VI. **ការធ្វើវិសោធនកម្ម**

ប្រការ ២២

១-គណៈប្រតិភូ អាចស្នើសុំធ្វើវិសោធនកម្ម លើកសំណើ ឬសេចក្តីព្រាងសេចក្តីសម្រេច ឬសំណើសុំធ្វើវិសោធនកម្មបន្ទាប់បន្សំ។

២-សំណើសុំធ្វើវិសោធនកម្ម ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ។ ការធ្វើវិសោធនកម្ម និងវិសោធនកម្មបន្ទាប់បន្សំ អាចស្នើបាន រហូតដល់ពេលមហាសន្និបាតអនុម័តទៅលើអត្ថបទដែលពាក់ព័ន្ធ។

### ប្រការ ២៣

១-សំណើធ្វើវិសោធនកម្ម និងវិសោធនកម្មបន្ទាប់បន្សំ ត្រូវតែទាក់ទងទៅនឹងសេចក្តីព្រាងអត្ថបទ។ សំណើសុំធ្វើវិសោធនកម្មទាំងនេះ អាចស្នើសុំបន្ថែម លុបចោល ឬកែប្រែនូវចំណុចណាមួយទៅលើសេចក្តីព្រាងដំបូង ដោយមិនអាចកែប្រែទៅលើវិសាលភាព ឬ អត្ថន័យទាំងស្រុងបានឡើយ។ ប្រធានមហាសន្និបាត ត្រូវកំណត់ថាតើ វិសោធនកម្ម និងវិសោធនកម្មបន្ទាប់បន្សំនេះ ដែលត្រូវបោះឆ្នោតសម្រេចនៅក្នុងមហាសន្និបាត មានលំដាប់លំដោយ។

២-សំណើសុំធ្វើវិសោធនកម្ម និងវិសោធនកម្មបន្ទាប់បន្សំ ត្រូវធ្វើការបោះឆ្នោត ឲ្យបានមុនអត្ថបទសេចក្តីព្រាងសេចក្តីសម្រេចដែលពាក់ព័ន្ធ។

### ប្រការ ២៤

១-ប្រសិនបើមានសំណើសុំធ្វើវិសោធនកម្មពីរ ឬច្រើនជាងនេះ ក្នុងន័យដូចគ្នា ទៅលើសេចក្តីព្រាងសេចក្តីសម្រេចមួយ ហើយដែលមានលក្ខណៈខុសឆ្ងាយពីសេចក្តីសម្រេចដើមដែលកំពុងពិចារណា ត្រូវមានអាទិភាពជាងសេចក្តីស្នើសុំការធ្វើវិសោធនកម្មផ្សេងទៀត និងត្រូវដាក់ឲ្យបោះឆ្នោតមុនគេ។ សេចក្តីសម្រេចចិត្តរបស់ប្រធានទាក់ទងទៅនឹងអាទិភាពវិសោធនកម្មនេះ គឺជាការសម្រេចចុងក្រោយ។

២-ប្រសិនបើសំណើសុំធ្វើវិសោធនកម្មចំនួន ០២ ឬច្រើនជាងនេះមិនជាន់គ្នា ការអនុម័តនូវសំណើទី ១ គឺត្រូវធ្វើការជំទាស់សំណើវិសោធនកម្មផ្សេងទៀត ឬសំណើវិសោធនកម្ម ដែលមានពាក្យដូចគ្នា។

### ប្រការ ២៥

មានតែម្ចាស់សំណើសុំធ្វើវិសោធនកម្ម ឬវិសោធនកម្មបន្ទាប់បន្សំប៉ុណ្ណោះ ដែលត្រូវឡើងអះអាង និងប្រតិភូម្នាក់ផ្សេងទៀត លើកគំនិតផ្ទុយទៅនឹងសំណើនោះ លើកលែងតែប្រធាន

សម្រេចថា ផ្តល់ឲ្យមានអ្នកនិយាយគាំទ្រ ០២ រូប និងអ្នកនិយាយប្រឆាំង ០២ រូប ចំពោះសំណើវិសោធនកម្ម ឬសំណើវិសោធនកម្មបន្ទាប់បន្សំនោះ។

## VII. ការឡើងបញ្ចេញមតិ លំដាប់លំដោយនៃការបញ្ចេញមតិ និងសំណើនៃនីតិវិធី

**ប្រការ ២៦**

១- គណៈប្រតិភូ មិនអាចឡើងបញ្ចេញមតិ ដោយគ្មានការអនុញ្ញាតិ្តពីប្រធានបានឡើយ។

២- តាមបទប្បញ្ញតទូទៅ គណៈប្រតិភូអាចឡើងសម្តែងមតិ តាមលំដាប់លំដោយដែលខ្លួនបានស្នើសុំ។

៣-វាគ្មិន អាចត្រូវផ្អាកដោយប្រតិភូផ្សេងទៀត យោងតាមលំដាប់ប៉ុណ្ណោះ។ ដោយមានការអនុញ្ញតពីប្រធានប្រតិភូ គេអាចប្រគល់វេទិកានេះជូនទៅកាន់គណៈប្រតិភូដែលបានលើកដៃ ដើម្បីស្នើសុំការបំភ្លឺណាមួយ។

៤-ប្រធាន ត្រូវធ្វើការសម្រេចភ្លាមៗ ដោយគ្មានការជជែកពិភាក្សាគ្នាទៅលើគ្រប់ចំណុចទៅតាមលំដាប់។

**ប្រការ ២៧**

១- នៅក្នុងកិច្ចពិភាក្សាទូទៅ (General Debate) មិនអនុញ្ញាតឲ្យមានអ្នកតំណាងលើសពីពីរនាក់ពីគណៈប្រតិភូនីមួយៗឡើងថ្លែងបានទេ វាលែងតែភ្នាក់ងារដឹកនាំអង្គប្រជុំសម្រេចផ្សេងពីនេះ។ បើមិនដូច្នោះទេ គណៈប្រតិភូទាំងអស់ មានថេរវេលាត្រឹមតែ១០នាទីប៉ុណ្ណោះសម្រាប់ធ្វើអត្ថាធិប្បាយនៅក្នុងកិច្ចពិភាក្សាជាទូទៅ។ នៅពេលដែលមានវាគ្មិនពីរនាក់ មកពីគណៈប្រតិភូដូចគ្នា បានចុះឈ្មោះដើម្បីឡើងបញ្ចេញមតិក្នុងកិច្ចពិភាក្សា ពួកគេត្រូវចែករំលែកពេលវេលាគ្នានិយាយ ដោយវិធីសមស្របបំផុត។

២-ដើម្បីធានាថា កិច្ចពិភាក្សាខាងលើមានភាពរលូន ភ្នាក់ងារដឹកនាំកិច្ចប្រជុំអាចធ្វើការផ្លាស់ប្តូរពេលវេលានិយាយ ឲ្យសមតាមកាលៈទេសៈ។

៣-ថ្វីត្បិតតែមាន ការចែងនៅក្នុងវាក្យខ័ណ្ឌទី១ ខាងលើក៏ដោយ នៅពេលចុងបញ្ចប់នៃកិច្ចពិភាក្សា ប្រធានអង្គប្រជុំ អាចប្រគល់វេទិកាដែលមានរយៈពេល០៣នាទីជូនគណៈប្រតិភូណាម្នាក់ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតប។

## ប្រការ ២៨

ប្រធានអង្គប្រជុំ អាចបញ្ជាឲ្យវាគ្មិនរក្សាសណ្តាប់ធ្នាប់ នៅពេលណាដែល វាគ្មិនណាម្នាក់នោះ និយាយចាកប្រធានបទដែលកំពុងពិភាក្សា ឬធ្វើបុរេវិនិច្ឆ័យទៅលើកិច្ចពិភាក្សានោះ ដោយប្រើប្រាស់ភាសារប្រមាថ ឬលើកឡើងពីបញ្ហា ដែលបង្ករឲ្យមានការបែកបាក់គ្នា។ ក្នុងករណីចាំបាច់ ប្រធានអង្គប្រជុំ អាចដកហូតសិទ្ធិក្នុងការធ្វើការអត្ថាធិប្បាយ និងស្នើសុំឲ្យលុបចោលទាំងស្រុងនូវពាក្យពេចន៍ជំទាស់ចេញពីកំណត់ត្រា។

## ប្រការ ២៩

១- ប្រធានអង្គប្រជុំ ត្រូវធ្វើការដោះស្រាយភ្លាមៗចំពោះឧប្បត្តិហេតុណាមួយដែលអាចកើតមានឡើង ក្នុងអំឡុងពេលកិច្ចប្រជុំ ហើយក្នុងករណីចាំបាច់ ត្រូវចាត់វិធានការណ៍មួយ ដើម្បីស្តារកិច្ចដំណើរមហាសន្និបាតឲ្យមានភាពរលូនឡើងវិញ។

## ប្រការ ៣០

១-អាទិភាពចំពោះការឡើងសម្តែងមតិ ត្រូវផ្តល់ជូនគណៈប្រតិភូដែលមានបំណងចង់ស្នើដូចខាងក្រោម៖

ក) ផ្អាកកិច្ចពិភាក្សាត្រឹមហ្នឹងតែម្តង

ខ) ផ្អាកកិច្ចពិភាក្សា

គ) បិទ ឬបញ្ចប់បញ្ជីឈ្មោះវាគ្មិន

ឃ) បិត ឬផ្អាកកិច្ចប្រជុំ

ង) ស្នើដំណើការកិច្ចប្រជុំ។

២-សំណើទាក់ទងនឹងនីតិវិធី ត្រូវមានអាទិភាពខ្ពស់ជាងសំណួរទាក់ទងនឹងខ្លឹមសារ។ ការពិភាក្សាលើសំណួរទាក់ទងនឹងខ្លឹមសារ អាចត្រូវលើកទៅពេលក្រោយ ហើយសំណួរទាក់ទងនឹងនីតិវិធី ត្រូវលើកយកមកពិភាក្សា។

៣-ម្ចាស់សំណើ ត្រូវធ្វើបទបង្ហាញសង្ខេប អំពីសំណើរបស់ខ្លួន ដោយមិនផ្តោតទៅលើខ្លឹមសារសំណួរនៅក្នុងកិច្ចពិភាក្សានោះទេ។

៤-នៅក្នុងការជជែកពិភាក្សាអំពីសំណើទាក់ទងនឹងនីតិវិធី មានតែម្ចាស់សំណើ និងប្រតិភូដែលលើកគំនិតផ្ទុយគ្នាម្នាក់ប៉ុណ្ណោះ ត្រូវបានទទួលចម្លើយក្រោយពីកិច្ចពិភាក្សាពេញអង្គធ្វើការសម្រេច។

**ប្រការ ៣១**

កិច្ចពិភាក្សានៅក្នុងមហាសន្និបាត ត្រូវធ្វើឡើងជាសាធារណៈ។ កិច្ចពិភាក្សាអាចត្រូវ ធ្វើឡើងជាសម្ងាត់ លើកលែងតែមហាសន្និបាតធ្វើការសម្រេចផ្សេងក្រៅពីនោះ ដោយសំឡេង២/៣ នៃគណៈប្រតិភូដែលចូលរួម ដោយបោះឆ្នោត។

## VIII. កូរ៉ុម មតភាគច្រើន ការបោះឆ្នោត

**ប្រការ ៣២**

១-មហាសន្និបាត អាចចាប់ផ្តើមបាន លុះត្រាមានសភាជាសមាជិកយ៉ាងតិចពាក់កណ្តាលនៃចំនួនសមាជិកបានចូលរួមក្នុងអង្គប្រជុំ។

២-កូរ៉ុមត្រូវបានបង្កើតឡើងនៅលើមូលដ្ឋាននៃចំនួនគណៈប្រតិភូដែលបានចូលរួមក្នុងសម័យប្រជុំពេញអង្គដំបូង។ លេខាធិការដ្ឋាន នឹងធ្វើការប្រកាសចំនួនកូរ៉ុមនាពេលនោះ។

**ប្រការ ៣៣**

១- សេចក្តីសម្រេចចិត្ត និងការសម្រេចទាំងអស់ នៃកិច្ចប្រជុំពេញអង្គត្រូវបានអនុម័តតាមតែអាចធ្វើទៅបាន គឺឈរលើមតិឯកច្ឆ័នភាគច្រើន។ បើមិនដូចនោះទេ អង្គប្រជុំត្រូវធ្វើការអនុម័ត ដោយសំឡេងបោះឆ្នោតភាគច្រើន នៃចំនួនគណៈប្រតិភូដែលបានចូលរួម និងបានបោះឆ្នោត (មាត្រាទី១១ នៃធម្មនុញ្ញ) លើកលែងតែករណីតម្រូវឲ្យមានសំឡេងភាគច្រើនលើសលុប។ ត្រូវបានស្នើឡើង សម្រាប់ការបោះឆ្នោត។

២-បន្ថែមពីលើករណីនេះ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះ មហាសន្និបាត ដោយផ្អែកលើសម្លេងឆ្នោតភាគច្រើននៃចំនួនគណៈប្រតិភូដែលបានចូលរួម និងបានបោះឆ្នោត អាចសម្រេចថា ប្រធានបទណាមួយ ត្រូវការសម្លេងអនុម័ត ដោយសម្លេងភាគច្រើនលើសលុប (មាត្រាទី ១១ នៃធម្មនុញ្ញ)។

**ប្រការ ៣៤**

១-គណៈប្រតិភូនីមួយៗ មានសិទ្ធក្នុងការបោះឆ្នោត ដោយផ្អែកទៅលើចំនួននៃគណៈប្រតិភូរបស់ខ្លួនដែលបានចូលរួមក្នុងមហាសន្និបាត។ គណៈប្រតិភូម្នាក់មាន ០១ សំឡេង (មាត្រា ៨ នៃធម្មនុញ្ញ)។

២-មានតែគណៈប្រតិភូដែលមានវត្តមាន និងចូលរួមប៉ុណ្ណោះទើបមានសិទ្ធបោះឆ្នោត។

៣-ប្រធានសភា នៃសភាសមាជិក ដែលដឹកនាំគណៈប្រតិភូចូលរួមនៅក្នុងមហាសន្និបាត មានសំឡេងបោះឆ្នោត ០១សំឡេង បន្ថែមទៅលើចំនួនសម្លេងដែលសមាជិកប្រតិភូរបស់ខ្លួនមានសិទ្ធិបោះឆ្នោត យោងតាមវាក្យខ័ណ្ឌ ០១ ខាងលើ។

**ប្រការ ៣៥**

តារាង ដែលបង្ហាញអំពីចំនួនសម្លេងនៃការបោះឆ្នោតដែលសមាជិកប្រតិភូចូលរួមមហាសន្និបាត ត្រូវបានចែកជូនក្នុងពេលបើកសម័យប្រជុំ។

**ប្រការ ៣៦**

១-ជាធម្មតា មហាសន្និបាតត្រូវធ្វើការបោះឆ្នោត តាមរយៈការលើកដៃ ឬក្រោកឈរ។ ប្រសិនបើប្រធានយល់ឃើញថា មានការចាំបាច់ ឬមានការស្នើសុំពីគណៈប្រតិភូឲ្យមានការបោះឆ្នោតដោយការហៅឈ្មោះប្រតិភូ ពេលនោះគេអាចត្រូវប្រើឧបករណ៍អេឡិចត្រូនិច ឬបោះឆ្នោតជាសម្ងាត់។

២-នៅក្នុងការរាប់ចំនួនសន្លឹកឆ្នោត ដោយ "ផ្អែកលើចំនួនគណៈប្រតិភូដែលចូលរួម និងបានបោះឆ្នោត" សន្លឹកឆ្នោតដែលបានការ គឺ សន្លឹកឆ្នោត ដែលបង្ហាញថា វិជ្ជមាន ឬ អវិជ្ជមានតែប៉ុណ្ណោះ។

៣-ប្រសិនបើការបោះឆ្នោត ត្រូវបានបង្ហាញដោយមានសំឡេងគាំទ្រស្មើគ្នា នោះសំណើនណាដែលស្ថិតក្នុងការពិចារណានោះ ត្រូវបានចាត់ទុកថា ត្រូវបានបដិសេធ។

**ប្រការ ៣៧**

១-ក្នុងករណីមិនទទួលបានមតិឯកច្ឆ័ន្ទ មហាសន្និបាត ត្រូវធ្វើការបោះឆ្នោតទៅលើអត្ថបទនៃការសម្រេច ឬសេចក្តីព្រាងសេចក្តីសម្រេចដែលបានដាក់ស្នើសុំ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមិនពិភាក្សាទៅលើខ្លឹមសារនោះឡើយ។

២-មិនមានការបើកចំហរឲ្យមានកិច្ចពិភាក្សាណាមួយ ត្រូវបានធ្វើឡើង និងបោះឆ្នោតទៅលើសំណួរណាមួយដែលមហាសន្និបាត បានធ្វើការពិចារណា ឬសម្រេចចិត្តរួចមកហើយនោះទេ។ ក្នុងករណីពិសេស មហាសន្និបាត អាចសម្រេច ដោយមានមតិគាំទ្រ ២/៣ នៃគណៈប្រតិភូដែលបានចូលរួម ដោយការបោះឆ្នោត ដើម្បីធ្វើការបើកឲ្យមានកិច្ចពិភាក្សា និងពិនិត្យសារជាថ្មីទៅលើសេចក្តីសម្រេចដែលបានធ្វើរួចហើយ។

**ប្រការ ៣៨**

១-គណៈប្រតិភូណាមួយ អាចស្នើទៅមហាសន្និបាតឲ្យមានការបោះឆ្នោតដាច់ដោយឡែកពីគ្នាចំពោះសំណើលើផ្នែកណាមួយ វាក្យខ័ណ្ឌ ឬអត្ថបទណាមួយដែលបានដាក់ស្នើទៅកាន់មហាសន្និបាត។

២-ប្រសិនបើ មានការជំទាស់ណាមួយលើកឡើងនោះការស្នើសុំដែលបានលើកឡើងត្រូវធ្វើការបោះឆ្នោត ដោយមិនចាំបាច់មានការពិភាក្សាវែកញែកឡើយ។

**ប្រការ ៣៩**

១-ប្រតិភូណាក៏ដោយ មិនអាចរំខានដល់ដំណើរការបោះឆ្នោត នៅពេលដែលចាប់ផ្តើមនោះទេ លើកលែងតែការស្នើសុំឲ្យមានការបញ្ជាក់អំពីលក្ខណៈ និងនីតិវិធី នៃដំណើរការបោះឆ្នោតប៉ុណ្ណោះ។

២-គណៈប្រតិភូ ដែលមានបំណងធ្វើការពន្យល់បកស្រាយអំពីការបោះឆ្នោតរបស់ខ្លួនដោយសង្ខេប អាចត្រូវបានផ្តល់សិទ្ធិ ដើម្បីពន្យល់បកស្រាយ ដោយមានការអនុញ្ញាតពីប្រធាន និងនៅក្រោយពេលដែលការបោះឆ្នោតត្រូវបានបញ្ចប់។

៣-មិនមានការបកស្រាយណាមួយអំពីការបោះឆ្នោត ត្រូវបានផ្តល់ជូនឡើយ ទៅលើការធ្វើវិសោធនកម្ម និងសំណើនីតិវិធី។

## IX. លេខាធិការដ្ឋានអចិន្ត្រៃយ៍ និងលេខាធិការដ្ឋានបណ្តោះអាសន្ន

**ប្រការ ៤០**

ការិយាល័យកណ្តាលនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់សភាតំបន់អាស៊ី មានទីតាំងនៅក្នុងទីក្រុងតេអេរ៉ង់។ មហាសន្និបាត នឹងសម្រេចលើបញ្ហានានាទាក់ទងនឹងថវិកា និងបុគ្គលិកសម្រាប់លេខាធិការដ្ឋានអចិន្ត្រៃយ៍សភាតំបន់អាស៊ីនៅឆ្នាំ២០១១។

**ប្រការ ៤១**

ប្រធានរបស់សភាតំបន់អាស៊ី ត្រូវរៀបចំលេខាធិការដ្ឋានបណ្តោះអាសន្នមួយនៅក្នុងប្រទេសជាម្ចាស់ផ្ទះ ដើម្បីរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាត។

**ប្រការ ៤២**

១-លេខាធិការដ្ឋានអចិន្ត្រៃយ៍ ដឹកនាំដោយអគ្គលេខាធិការមួយរូប ត្រូវជួយប្រធាន និងលេខាធិការដ្ឋានបណ្តោះអាសន្នដឹកនាំការងារកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាត។

២-នៅពេលណាមានការស្នើសុំពីប្រធាន អគ្គលេខាធិការ ឬតំណាងរបស់គាត់អាចលើកយោបល់ជូនមហាសន្និបាតទៅលើបញ្ហាណាមួយដែលកិច្ចប្រជុំកំពុងពិនិត្យពិចារណា។

**ប្រការ ៤៣**

១-លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវទទួលរាល់ឯកសារ របាយការណ៍ និងសេចក្តីព្រាងសេចក្តីសំរេចទាំងអស់ ហើយត្រូវចែកជូនសភាសមាជិកទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍សង្ខេប នៃកិច្ចប្រជុំ ជាភាសារការងាររបស់សភាតំបន់អាស៊ី និងជាភាសាអារ៉ាប់។

២-លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃមហាសន្និបាត ត្រូវតែធានាថា មានសម្ភារៈបច្ចេកទេសគ្រប់គ្រាន់ សម្រាប់ធ្វើការបកប្រែប្រដេញជាភាសាអង់គ្លេសនិងភាសាអារ៉ាប់ និងសម្រាប់គណៈប្រតិភូដែលមានបំណងចង់និយាយជាភាសាជាតិរបស់ខ្លួន និងមានអ្នកបកប្រែប្រដេញជាភាសាអង់គ្លេសផ្ទាល់ខ្លួនឯង។

៣ ដោយមានការសម្របសម្រួលជាមួយលេខាធិការអចិន្ត្រៃយ៍ លេខាដ្ឋានបណ្តោះអាសន្នត្រូវធានាផ្តល់នូវសម្ភារៈគ្រប់គ្រាន់ សម្រាប់រៀបចំទទួលគណៈប្រតិភូ ឲ្យបានសុខស្រួល និងធានាបំពេញដល់កាតព្វកិច្ចរបស់ប្រតិភូដោយរលូននៅក្នុងប្រទេសជាម្ចាស់ផ្ទះ។

**ប្រការ ៤៤**

១-លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់សភាតំបន់អាស៊ី ត្រូវរក្សាទុករាល់ឯកសាររបស់ក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតនៅក្នុងប័ណ្ណសារដ្ឋានរបស់ខ្លួន។ លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវធ្វើការតាមដានលើការអនុវត្តសេចក្តីសម្រេចចិត្ត របស់មហាសន្និបាត និងជាទូទៅត្រូវអនុវត្តគ្រប់កិច្ចការ នៅពេលដែលកិច្ចប្រជុំពេញអង្គគិតថា អាចជឿទុកចិត្តបាន (មាត្រាទី១៣ នៃធម្មនុញ្ញសភាតំបន់អាស៊ី)។

២-លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវធ្វើការបោះពុម្ពរាល់ឯកសារនៃមហាសន្និបាត និងចែកជូនសភាសមាជិក និងអ្នកសង្កេតការណ៍។

**ប្រការ ៤៥**

ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សាប្រតិបត្តិ និងការឯកភាពពីមហាសន្និបាត អគ្គលេខាធិកា ត្រូវធ្វើការបោះឆ្នោតសម្រាប់អាណត្តិរយៈពេល ០៤ឆ្នាំ ពីក្នុងឥស្សរជន នៅក្នុងអនុតំបន់នានា នៃតំបន់អាស៊ី។

## X. ការបិទមហាសន្និបាត

**ប្រការ ៤៦**

១-នៅពេលបិទមហាសន្និបាតនីមួយៗ ប្រធាន ត្រូវធ្វើការប្រកាស និងអាននូវសេចក្តីសម្រេច និងការសម្រេចចិត្តសំខាន់ៗដែលបានអនុម័ត។

២-គណៈប្រតិភូទាំងអស់ ត្រូវជម្រាបទៅដល់សភា និងរដ្ឋាភិបាលរបស់គេរៀងៗខ្លួន ឲ្យដឹងអំពីសេចក្តីសម្រេច ការសម្រេចចិត្ត និងអនុសាសន៍នានា ដែលមហាសន្និបាតបានអនុម័ត សំដៅទទួលបានការគាំទ្រក្នុងការអនុវត្តយ៉ាងសកម្មនូវសេចក្តីសម្រេច និងការសម្រេចចិត្តសំខាន់ៗ។

## XI. ការអនុម័ត និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុង

**ប្រការ ៤៧**

១-មហាសន្និបាត ត្រូវធ្វើការអនុម័តនូវបទបញ្ជាផ្ទៃក្នុងរបស់សភាតំបន់អាស៊ី តាមរយៈការបោះឆ្នោត ដោយមតិ ភាគច្រើនពីគណៈប្រតិភូដែលបានចូលរួមនិងបានបោះឆ្នោតដោយស្របទៅនឹងមាត្រា៣៣ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ។

២-សំណើសុំធ្វើវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុងរបស់សភាតំបន់អាស៊ី ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ដោយមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ និងផ្ញើទៅកាន់លេខាធិការដ្ឋានសភាតំបន់អាស៊ី យ៉ាងយូរបំផុត០៣ខែ មុនពេលដែលមហាសន្និបាតចាប់ផ្តើមឡើង។ លេខាធិការដ្ឋាន ត្រូវទំនាក់ទំនងភ្លាមៗជាមួយសភាសមាជិក។ ជាមួយគ្នានេះដែរ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន ត្រូវទំនាក់ទំនងជាមួយសភាជាសមាជិក អំពីសំណើធ្វើវិសោធនកម្មបន្ទាប់បន្សំឲ្យបានយ៉ាងតិច០១ខែ មុនពេលមហាសន្និបាតចាប់ផ្តើម។

៣-ការពិនិត្យលើសំណើណាមួយដើម្បីធ្វើវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុង ត្រូវ ដាក់បញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិនិងមហាសន្និបាត។

៤-សំណើសុំធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង ត្រូវធ្វើអនុម័តដោយសម្លេង ២/៣ នៃសភាសមាជិកដែលមានវត្តមាន ដោយការបោះឆ្នោត នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។ អនុសាសន៍របស់ក្រុមប្រឹក្សាប្រតិបត្តិចំពោះមហាសន្និបាតទៅលើសំណើសុំធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង ត្រូវធ្វើការអនុម័ត ដោយសម្លេងភាគច្រើន ដោយការបោះឆ្នោតពីប្រតិភូនៅក្នុងសម័យប្រជុំពេញអង្គ។